# ទស្សនៈអាជីវកម្ម គួច ម៉េងលី

## Mengly J. Quach's Business Concepts



ឧកញ៉ា វេជ្ជបណ្ឌិត
គួច ម៉េងលី ចាន់ឌី
Oknha Dr. Mengly
Jandy Quach

បោះពុម្ពឡើងវិញ

គ្រឹះស្ថានបោះពុម្ព
នៃសាកលវិទ្យាល័យ ម៉េងលី ជេ. គួច

MENGLY J. QUACH
University Press

គ.ស. ២០១៦

រក្សាសិទ្ធិគ្រប់យ៉ាង៖

គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបោះពុម្ពផ្សាយ
ថតចម្លង ដាក់បញ្ចូលក្នុងប្រព័ន្ធអេឡិកត្រូនិចគ្រប់ទម្រង់ រូបភាព
និងមធ្យោបាយ ព្រមទាំងបកប្រែទៅជាភាសាដទៃ ដោយគ្មាន
ការអនុញ្ញាតពីគ្រឹះស្ថានបោះពុម្ព នៃសាកលវិទ្យាល័យ
ម៉េងលី ជេ. គួច ឡើយ។ អំពើថតចម្លងស្នាដៃ
ធ្វើអាជីវកម្ម ជាអំពើខុសច្បាប់
និងខុសក្រមសីលធម៌។

និពន្ធដោយ៖ លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី
បណ្ណាធិការ៖ ឃឹម ច័ន្ទសុអហំ
រចនាទំព័រ៖ គួរ សុគីម
បោះពុម្ពឡើងវិញ ខែកញ្ញា គ.ស. ២០១៨ ភ្នំពេញ
បោះពុម្ពដោយ៖ គ្រឹះស្ថានបោះពុម្ព នៃសាកលវិទ្យាល័យ ម៉េងលី ជេ. គួច
អាសយដ្ឋាន៖ អគារលេខ១៨០ និង២១០ មហាវិថីម៉ៅសេទុង រាជធានីភ្នំពេញ
ទូរសព្ទ៖ ០២៣ ២២៣ ២៩៥, ០២៣ ២២១ ២២២, ០១១ ៣៨៨ ៨៦៨
និង ០៩៣ ២១៧ ២១៧
ទូរសារ៖ ០២៣ ៩៩៩ ៩៣០
អ៊ីមែល៖ info@mjqeducation.edu.kh
គេហទំព័រ៖ www.mjqeducation.edu.kh
រក្សាសិទ្ធិ៖ សាកលវិទ្យាល័យ ម៉េងលី ជេ. គួច, គ.ស. ២០១៦
ISBN-13: 978-9924-508-02-1

គំនិត យោបល់ ឬទស្សនៈនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធផ្ទាល់ ដែលមិនឆ្លុះបញ្ចាំងពីគំនិត យោបល់ ឬទស្សនៈរបស់គ្រឹះស្ថានបោះពុម្ព នៃសាកលវិទ្យាល័យ ម៉េងលី ជេ. គួច ឡើយ។

## ជូនចំពោះ

យុវជនដែលជាអ្នកកសាង
អនាគតដ៏អស្ចារ្យនៃ
ប្រទេសកម្ពុជា

# មាតិកា ទំព័រ


**កំណត់អ្នកបោះពុម្ពផ្សាយ** x
**សេចក្តីថ្លែងអំណរគុណ** xii
**អារម្ភកថា** xiii
**ជំពូកទី១**
**១. គុណភាព** ៣
*ក. ការអប់រំ* ៧
*ខ. កុំគិតតែពីសញ្ញាបត្រ* ១១
*គ. របនាសម្ពន្ធគ្រប់គ្រង* ១៧
*ឃ. យក៥ ធ្វើបាន១០* ២០
*ង. យកអ្នកពូកែជាងយើង មកធ្វើការជាមួយយើង* ២៣
*ច. ភាសា៧* ២៦
*ឆ. ការគ្រប់គ្រងបុគ្គលិក* ៣៣
**២. វិន័យ** ៤១
*ក. ៥ចំណុចដើម្បីការងារជោគជ័យ* ៤២
*ខ. ពេលបុគ្គលិកមានកំហុស (ឱ្យឱកាស)* ៤៦
*គ. ឱ្យធ្វើ "ក" កុំធ្វើ "ខ"* ៥០
*ឃ. មកមុន ទៅក្រោយ* ៥២
*ង. ការរៀបចំខ្លួន* ៥៥
**៣. សេវាកម្ម** ៥៩
*ក. យើងបម្រើសេវាកម្ម មិនមែនជាខ្ញុំកញ្ជះទេ* ៦១
*ខ. សេវាកម្មតម្រូវចិត្ត* ៦៤
*គ. កុំផ្តល់សេវាកម្មបែបបរទេសនិយម* ៦៨
**ជំពូកទី២**
**១. ទំនុកចិត្ត** ៧៣
*ក. សាមគ្គីភាព គឺជាភាពបរាជ័យ បើគ្មានឯករាជ្យភាព* ៧៣
*ខ. កុំនិយាយដើមគេ* ៧៨
*គ. ៣សំណួរសួរខ្លួនឯង* ៨៣

ឃ. “ទេ”មិនមានន័យថា“ទេ”“បាទ”មិនមានន័យថា“បាទ” ៨៨
ង. ប្រើបុគ្គលិកដោយទំនុកចិត្ត ៩២
ច. ចេះបត់បែន ៩៥
**២. គំនិតវិជ្ជមាន** **៩៩**
ក. ធ្វើតិចបានតិច ធ្វើច្រើនបានច្រើន ៩៩
ខ. កុំពូកែរៀន តែមិនពូកែចេះ ១០៣
គ. ឡើងកុំអឿ តឿកុំទាប ១០៧
ឃ. ទាបណាស់ ខ្ពស់ណាស់ ១១១
ង. ដឹកនាំខ្លួនឱ្យថ្លៃថ្នូ ១១៤
**៣. ការដឹកនាំចំពោះខ្ញុំ** **១១៧**
ក. ចិត្តសាស្ត្រផ្ទុយ ១១៧
ខ. មើលបញ្ហាឱ្យឃើញបញ្ហា ១១៩
គ. ចាត់ទុកបុគ្គលិកជាទ្រព្យសម្បត្តិ ១២២
ឃ. កុំធ្វើអាជីវកម្មតាមថ្លៃលិចថ្ងៃរះ ១២៥
ង. កុំប៉ែងដើងគ្នា ១២៩
ច. ប្រើមនុស្សឱ្យត្រូវជំនាញ ១៣២
ឆ. ទះស្គរឱ្យឮ ១៣៥
ជ. មេដឹកនាំខ្សែប៉េងប៉ោង ១៣៩
ឈ. គេជះភ្លើង យើងជះទឹក ១៤១
ញ. កំណត់ពេលវេលា ១៤៣
**ជំពូកទី៣**
ក. បរិច្ចាគមិនចាំពេល ១៥០
ខ. ធ្វើបុណ្យ ១៥៣
គ. ជួយបុគ្គលិក ១៥៥
**ជំពូកទី៤**
ក. ៥នាទី ១៦០
ខ. ចេះមើលឱកាស ចាប់ឱកាស និងបំបែកឱកាស ១៦៥
គ. ខាតក៏ដោយឲ្យតែចំណេញ ១៦៩
**អវសានកថា** **១៧២**

# កំណត់អ្នកបោះពុម្ពផ្សាយ

*ស្ទើរមិនដល់រយៈពេល៣ខែស្រួលបួលផង សៀវភៅខ្ញុំដែលមានចំណងជើងថា "ទស្សនៈអាជីវកម្ម" បោះពុម្ពលើកទី១ ចំនួន១០០០០ក្បាល កំលុងខែកក្កដា ឆ្នាំ២០១៦ នោះ បានលក់អស់ទាំងស្រុង ទើបជាហេតុជំរុញចិត្តឱ្យខ្ញុំសម្រេចបន្តបោះពុម្ពសៀវភៅនេះជាលើកទី២ ទៀតចំនួន ១០០០០ក្បាលបន្ថែមទៀត នៅចុងខែវិច្ឆិកា ឆ្នាំ២០១៦ នេះ ដើម្បីបំពេញសេចក្តីត្រូវការរបស់មិត្តអ្នកអានដោយរីករាយ។ ពិសេស ក៏គឺជាការឆ្លើយតបផងដែរ ទៅនឹងអ្វីដែលជាតម្រូវការរបស់សិស្ស និស្សិត និងអ្នកមានចំណាប់អារម្មណ៍ ប្រាថ្នាចង់ក្លាយជាអ្នកធ្វើជំនួញដ៏ជោគជ័យមួយចំនួនដែលបានស្នើសុំមកខ្ញុំដោយផ្ទាល់ ឱ្យមានការបោះពុម្ពជាលើកទី២បន្តទៀត ព្រោះដោយសំអាងថាពួកគេទាំងនោះពុំទាន់បានទិញអាននៅឡើយ។*

*ខ្ញុំពិតជាសោមនស្សក្រៃលែង ចំពោះស្វាមីកក្តិប្រិយមិត្តទាំងឡាយ ដែលតែងគាំទ្រសៀវភៅស្តីពីកម្រងទស្សនៈគ្រប់គ្រងអាជីវកម្ម ដែលជាបទពិសោធផ្ទាល់ខ្លួនរបស់ខ្ញុំបានឆ្លងកាត់ក្នុងដំណើរការអាជីវកម្មអស់រយៈពេលជាង ១១ឆ្នាំកន្លងមក ក្នុងនាមជាអ្នកជំនួញមួយរូបនោះ។ ខ្ញុំពិតជារំភើបចំពោះសមានចិត្តមួយនេះ។ រំភើបក៏ព្រោះសូម្បីតែខ្ញុំផ្ទាល់ ក៏មិននឹកស្មានដល់ដែរថា សៀវភៅដែលស្តែងឡើងពីបទពិសោធផ្ទាល់របស់ខ្ញុំមួយនេះ បានក្លាយ*

ជាសៀវភៅដែលលោកអ្នកចាប់អារម្មណ៍ និងទាក់ទាញអារម្មណ៍យ៉ាងផុសផុលដូច្នេះឡើយ។ អ្វីដែលរឹងរឹតតែពិសេសទៀតនោះ គឺខ្ញុំពិតជាភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះទឹកចិត្តប្រិយមិត្តអ្នកអានទាំងឡាយដែលស្ម័គ្រទទួលយកបទពិសោធផ្នែកជំនួញរបស់ខ្ញុំ ទុកដូចជាបទពិសោធជីវិតផ្ទាល់ខ្លួន ឬយកធ្វើជាមេរៀនជីវិតដើម្បីអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាបុគ្គលដ៏ជោគជ័យក្នុងពិភពជំនួញនាពេលខាងមុខ។

ថ្វីបើយ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែទទូចបន្តស្នើចិត្តមិត្តអ្នកអានទាំងអស់ មេត្តាអនុគ្រោះដល់បទពិសោធជីវិតផ្នែកជំនួញរបស់ខ្ញុំផងចុះ នៅចំណុចណាដែលមិនសមទំនងនឹងទឹកចិត្តលោកអ្នក ក៏ព្រោះនេះ គឺដូចអ្វីដែលខ្ញុំបានថ្លែងរួចហើយថា វាគ្រាន់តែជាចំណែកមួយនៃជីវិតជំនួញផ្ទាល់ខ្លួនរបស់ខ្ញុំប៉ុណ្ណោះ។

តាមរយៈសៀវភៅមួយក្បាលនេះ ខ្ញុំសូមធ្វើការបួងសួងឱ្យជីវិតជំនួញប្រិយមិត្តអ្នកអានទាំងអស់ ជោគជ័យគ្រប់កាលៈទេសៈ។

ដោយសេចក្តីគោរពស្រឡាញ់រាប់អានដ៏ស្មោះពីខ្ញុំ!

ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមការងារដែលបានចូលរួមយ៉ាងសស្រាក់សស្រាំដើម្បីចងក្រងសៀវភៅនេះ។ សូមអរគុណគ្រឹះស្ថានបោះពុម្ពនៃសាកលវិទ្យាល័យ ម៉េងលី ជេ. គួច ដែលបានបោះពុម្ពសៀវភៅខ្ញុំជាសាធារណៈ។ ខ្ញុំពិតជាពេញចិត្តសៀវភៅនេះក្រៃលែង។

ការគាំទ្រ ជំនឿចិត្ត និងមគ្គុទ្ទេសក៍ដែលខ្ញុំបានទទួលតាមរយៈការបង្កើតសៀវភៅនេះឱ្យលេចចេញជារូបរាងពិតជាមេរៀនដ៏វិសេសមួយចំពោះខ្ញុំ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះមិត្តអ្នកអានទាំងឡាយដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីអានសៀវភៅ "ទស្សនៈអាជីវកម្មគួច ម៉េងលី" នេះ។ យោងតាមរយៈអ្វីដែលស្ដែងចេញពីបទពិសោធផ្ទាល់របស់ខ្ញុំក្នុងដំណើរជីវិតជាអ្នកអប់រំ និងអ្នកជំនួញ ខ្ញុំសង្ឃឹមថាអត្ថបទនេះនឹងអាចចូលរួមចំណែកតិចក្ដី ច្រើនក្ដីជួយដល់អ្នកទាំងអស់គ្នាឲ្យមានការរីកចម្រើនលើសមត្ថភាពយល់ដឹងផ្នែកអាជីវកម្មឱ្យកាន់តែរីកសាយទូលំទូលាយ និងចូលរួមចំណែកជួយសង្គមជាតិយើងឱ្យមានការអភិវឌ្ឍដើម្បីមានភាពជឿនលឿនខ្លាំងនាពេលអនាគត។ ដោយសេចក្ដីគោរពស្រឡាញ់រាប់អាន!

ពីខ្ញុំ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

# អារម្ភកថា

ជាការពិតណាស់ បើយើងប្រៀបធៀបប្រទេសយើងសព្វថ្ងៃ គឺឃើញថាមានប្រទេសខ្លះកំពុងឋិតនៅកម្រិតដូចយើង ហើយក៏មានប្រទេសជាច្រើនទៀតមានការរីកចម្រើនហួសឆ្ងាយពីយើង នៅក្នុងវិស័យផ្សេងៗជាច្រើន។ បច្ចុប្បន្នប្រទេសយើង គឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនដែលបានដឹង និងបានត្រៀមខ្លួនរួចរាល់ចំពោះសមាហរណកម្មថ្មី និងត្រៀមខ្លួនដើម្បីប្រជែងនឹងចរន្តសាកលភាវូបនីយកម្ម។ ការណ៍ទាំងនេះ គឺបានមកដោយសារធនធានមនុស្សពីគ្រប់វិស័យ ពិសេសវិស័យពាណិជ្ជកម្មនិងជំនួញ ព្រោះថាគឺយើងមានសហគ្រិននិងអ្នកជំនួញថ្មីៗដែលជាយុវជនដ៏មានសក្តានុពល និងមានឆន្ទៈមោះមុតដែលត្រៀមខ្លួនធ្វើជាមេដឹកនាំអាជីវកម្មដ៏ឆ្នើមនាពេលអនាគតដើម្បីចូលរួមចំណែកលើកតម្កើងសេដ្ឋកិច្ចជាតិ និងកិត្យានុភាពជាតិ។

ដើម្បីអភិវឌ្ឍខ្លួនឱ្យបានក្លាយជាអ្នកជំនួញដ៏ជោគជ័យ និងមានលក្ខណៈពិសេសជាងអ្នកជំនួញធម្មតា គឺទាមទារឱ្យយើងធ្វើរឿងជាច្រើនទើបសម្រេចលទ្ធផល ប៉ុន្តែគួរឱ្យស្តាយ អ្នកជំនួញថ្មីៗវ័យក្មេងជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ក្នុងនោះមានកម្ពុជាដែរ នៅមានកង្វះខាតមួយចំនួនទាក់ទងនឹងការស្វែងរកចម្លើយឆ្លើយតបនឹងសំណួរដូចជា តើអ្វីទៅជាចំណុចចាប់ផ្តើម? តើត្រូវចាប់ផ្តើម

ពីត្រង់ចំណុចណា និងដោយរបៀបណា? ហើយថាតើត្រូវចាប់ផ្តើមធ្វើនូវអ្វីមុនគេ?

មានរូបមន្តសាមញ្ញបំផុតមួយចំនួនដើម្បីឈានទៅដល់ជោគជ័យ។ ក្នុងនាមខ្ញុំជាអ្នកជំនួញម្នាក់ ខ្ញុំក៏ធ្លាប់មានជំនឿដូចអ្នកដែលកំពុងតែកាន់សៀវភៅនេះអានផងដែរ។ ខ្ញុំបានចូលរួមក្នុងវេទិកាសាធារណៈ ក្លិបសិក្សា ឬសិក្ខាសាលានានាជាច្រើន។ កាលណោះខ្ញុំក៏បានគិតដូចដែលអ្នករាល់គ្នាកំពុងគិតដូច្នោះដែរ គឺខ្ញុំចង់ចេះ ខ្ញុំចង់ដឹង និងខ្ញុំចង់យល់។ ប៉ុន្តែខ្ញុំសូមរម្លឹកអ្នកទាំងអស់គ្នាអំពីរឿងមួយ ដែលខ្ញុំទទួលបានពីការដាក់ទុនពេលវេលាដើម្បីប្តូរយកមកបាននោះគឺថា ទោះបីជាអ្នកធ្លាប់បានចូលរួមក្នុងវេទិកាសាធារណៈនានាច្រើនកម្រិតណាក៏ដោយ ប្រសិនបើអ្នកមិនប្រាកដក្នុងចិត្តពីអ្វីដែលអ្នកចង់បាន និងមិនប្រាកដក្នុងចិត្តពីអ្វីដែលអ្នកចង់រៀនសូត្រ នោះការចូលរួមទាំងអស់នោះ គឺប្រៀបបាននឹងការចំណាយពេលដ៏អត់ប្រយោជន៍បំផុត។ ប៉ុន្តែសូមចាំថា ទាំងនេះគ្រាន់តែជាពិសោធផ្ទាល់ខ្លួនដែលខ្ញុំឆ្លងកាត់ក្នុងដំណើរការអាជីវកម្មខ្ញុំប៉ុណ្ណោះ។

ម្យ៉ាងវិញទៀតដើម្បីគ្រប់គ្រងជំនួញឱ្យបានល្អ អ្នកមិនត្រឹមតែធ្វើ "A" ទេ តែអ្នកត្រូវធ្វើដល់ "B" និង "C" ទៀត។ ប៉ុន្តែបើអ្នកចង់ក្លាយជាអ្នកជំនួញជោគជ័យនាថ្ងៃក្រោយ អ្នកត្រូវធ្វើឱ្យបានតាំងពី "A" ដល់ "Z"។ អ្នកត្រូវចេះឈឺឆ្អាលទាំងអស់ មានន័យថាធ្វើឱ្យលើសពីដែនកំណត់ គោលដៅ

និងគម្រោងផែនការការងារដែលយើងកំពុងបិតនៅ។ មិនមែនមានន័យថា មានប៉ុណ្ណឹងនៅតែធ្វើប៉ុណ្ណឹងនោះទេ អ្នកត្រូវធ្វើឱ្យលើសពីហ្នឹងទៅទៀត ពោលគឺត្រូវលូតលាស់ឱ្យធំជាងប្រអប់ដែលយើងកំពុងបិតនៅ ហើយទៅឱ្យហួសពីដែនដែលយើងបានដៅទុក និងត្រូវទៅឱ្យផុតពីដែនដែលអ្នកដទៃទៅដល់។ អ្នកត្រូវដឹងថា នរណាក៏អាចធ្វើជាអ្នកជំនួញបានដែរ ប៉ុន្តែមិនមែនមានន័យថា គ្រប់គ្នាសុទ្ធតែអាចក្លាយជាអ្នកជំនួញជោគជ័យនោះទេ។ បើចង់ក្លាយជាអ្នកជំនួញជោគជ័យ គួរឱ្យគោរពស្រឡាញ់ និងអាចឱ្យគេសហការដោយរីករាយ និងប្រកបដោយទំនុកចិត្ត អ្នកគួរតែត្រូវបេះក្រឡេកភ្នែកមើលពិភពលោកឱ្យជុំ ហើយដឹកនាំការងារឱ្យប្រកបដោយមហិច្ឆតាខ្ពស់ និងប្រកបដោយគតិបណ្ឌិត។

ខ្ញុំពិតជាសោមនស្សក្រៃលែងដែលមានឱកាសបានចែករំលែកនូវគំនិត ទស្សនៈ និងបទពិសោធជីវិតតាមរយៈសៀវភៅនេះ។ មិត្តអ្នកអានទាំងអស់អាចទទួលយកនូវបទពិសោធនៃកម្រងទស្សនៈគ្រប់គ្រងអាជីវកម្មនេះ ទុកជាមរតកដួងចិត្តឬជីវិតផ្ទាល់ខ្លួនបាន។ ខ្ញុំក៏ស្នើចិត្តជាមុនដែរថា សូមមិត្តអ្នកអានចាត់ទុកថានេះគ្រាន់តែជាកម្រងទស្សនៈស្ដីពីជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលខ្ញុំបានឆ្លងកាត់ក្នុងដំណើរការអាជីវកម្មរបស់ខ្ញុំប៉ុណ្ណោះ។

ដ្បិតថាសៀវភៅដែលនៅក្នុងដៃអ្នកនេះ គឺជាកម្រង ទស្សនៈគ្រប់គ្រងអាជីវកម្មដែលកើតចេញពីពិសោធន៍ អាជីវកម្មរយៈពេល១១ឆ្នាំរបស់ខ្ញុំក៏ពិតមែន ប៉ុន្តែខ្ញុំជឿជាក់ ថា សៀវភៅនេះផ្ទុកពេញទៅដោយជំនឿចិត្ត សីលធម៌ សេចក្តីសោមនស្ស សុទិដ្ឋិនិយម និងសេចក្តីស្មោះត្រង់ ដែលយើងអាចអនុវត្តក្នុងសង្គមជាក់ស្តែង ដើម្បីធ្វើឱ្យ អ្វីៗគ្រប់យ៉ាងកាន់តែប្រសើរឡើង ពិសេសក្នុងមុខជំនួញ របស់អ្នក។

ខ្ញុំពិតជាជឿលើពំនោលសប្បុរសដែលបានពោលថា ការ ឱ្យអាហារ គឺជាទានដ៏ប្រសើរហើយ តែការឱ្យវិជ្ជាជាទាន នោះរឹងរឹតតែប្រសើរថែមទៀត ដ្បិតអីទានជាអាហារអាច ឱ្យគេឆ្អែតតែមួយខណៈប៉ុណ្ណោះ ប៉ុន្តែទានជាវិជ្ជាវិញ គឺ ឆ្អែតមួយជីវិត។ ខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំដែរថា ការចែក រំលែកនិងការផ្លាស់ប្តូរចំណេះដឹង ព្រមទាំងគំនិត មិនថា ធ្វើឡើងពីមួយទៅមួយ ឬធ្វើឡើងជាមួយក្រុមយុវជនទេ នោះគឺជាវិធីមួយក្នុងចំណោមវិធីដ៏ល្អជាច្រើនទៀតដើម្បី ចែករំលែកនូវគ្រាប់ពូជចំណេះដឹងទៅដល់កូនចៅជំនាន់ ក្រោយរបស់យើង។

ខ្ញុំសូមអរគុណចំពោះសមានចិត្តអ្នកទាំងអស់គ្នាដែល ជឿជាក់ និងបើកចិត្តទទួលយកពិសោធជីវិតខ្ញុំតាមរយៈ សៀវភៅនេះ។ សូមជូនពរអ្នកទាំងអស់គ្នាប្រកបតែសុខភាព ល្អ សេចក្តីសុខ និងសុភមង្គលក្នុងដំណើរជីវិតជាដរាប។

គិតល្អ អារម្មណ៍ល្អ
និងមើលអ្វីគ្រប់យ៉ាងក្នុងផ្លូវល្អ
នោះវានឹងនាំមកនូវសេចក្ដីល្អ
នៅក្នុងជីវិតរបស់អ្នក

# ជំពូកទី១

## ប្រតិបត្តិការជំនួញ
## (ការគេចវាងមុខដ្ឋានគ្រឹះ)

# ១. គុណភាព

ខ្ញុំជឿថា គ្រប់បុគ្គលជោគជ័យតែងតែខិតខំប្រឹងប្រែងគ្រប់មធ្យោបាយ ដើម្បីរក្សាក្រុមហ៊ុនឱ្យមានស្ថិរភាពនិងពង្រឹងគុណភាពឱ្យកាន់តែប្រសើរឡើងជាលំដាប់។ ប៉ុន្តែរឿងសំខាន់ចំពោះមុខបំផុតនោះ គឺយើងត្រូវពង្រឹងជំហរខ្លួនឯង និងបុគ្គលិកឱ្យកាន់តែរឹងមាំ ដោយចាប់ផ្តើមពីការឈានមួយជំហានម្តងៗ។ នៅត្រង់នេះគឺខ្ញុំចង់មានន័យថាជំហានដំបូងយើងត្រូវធ្វើខ្លួនឱ្យក្លាយជាបុគ្គលដែលមានគុណភាព បន្ទាប់មកអភិវឌ្ឍបុគ្គលិកយើងឱ្យកាន់តែមានគុណភាព ហើយនៅពេលជាមួយគ្នានោះ ស្ថាប័នទាំងមូលរបស់យើងក៏នឹងមានគុណភាពទៅតាមនោះដែរ។

បើនិយាយពីរឿងគុណភាព ខ្ញុំតែងក្រើនរម្លឹកបុគ្គលិកខ្ញុំជារឿយៗថា ដើម្បីធ្វើខ្លួនជាបុគ្គលប្រកបដោយគុណភាព និងជោគជ័យក្នុងអាជីពការងាររបស់ខ្លួន អ្នកត្រូវជ្រើសរើសការងារណាដែលអ្នកស្រឡាញ់ចូលចិត្ត មានចំណេះដឹងជំនាញ និងបទពិសោធ ហើយអ្នកត្រូវតែធ្វើការងារនោះឱ្យលះ មោះមុត តស៊ូ អត់ធ្មត់ នោះការងាររបស់អ្នកនឹងទទួលបានជោគជ័យ និងកម្រុបរាជ័យណាស់។ មានន័យថា នៅពេលអ្នកធ្វើអ្វីដែលខ្លួនយើងមានការចូលចិត្ត មានចំណេះដឹង មានបទពិសោធ ហើយច្បាស់លាស់ប្រាកដ

ប្រជាជាមួយការងារ នោះអ្នកកម្របរាជ័យណាស់។ បើអ្នកធ្វើអ្វីមួយដែលអ្នកមានចំណេះដឹងជ្រៅជ្រះ មានភាពចាស់ទុំ មានបទពិសោធ បូករួមនឹងអាកប្បកិរិយាល្អថែមទៀតនោះ ខ្ញុំអាចនិយាយបានថា អ្នកនឹងជោគជ័យជាក់ជាមិនខាន។

ចំពោះខ្ញុំដែលជាអ្នកវិនិយោគលើវិស័យអប់រំ បើនិយាយពីគុណភាព នោះគឺមានច្រើនចំណុចណាស់។ ឧទាហរណ៍ថា ខ្ញុំគិតទៅលើគុណភាពនៃអគារសិក្សាទៅចុះ អ៊ីចឹងយើងត្រូវសួរថា តើសំណង់អគារសិក្សារបស់យើងមានគុណភាពស្របតាមស្តង់ដារកម្រិតណាដែរ? ឯបន្ទប់រៀនវិញមានគ្រប់គ្រាន់សមាមាត្រនឹងចំនួនសិស្សដែរឬទេ? បើមានគ្រប់គ្រាន់ហើយ តើបន្ទប់នោះមានផាសុកភាពដូចម្តេចដែរ? មួយវិញទៀត បើនិយាយពីគុណភាពគ្រូវិញយើងត្រូវដឹងថា តើយើងមានគ្រូគ្រប់គ្រាន់ហើយឬនៅ? តើគ្រូៗទាំងនោះមានចំណេះដឹង និងមានគរុកោសល្យក្នុងការបង្រៀនច្បាស់លាស់កម្រិតណា? ហើយការបង្រៀនទៀតសោត តើគាត់យកចិត្តទុកដាក់ និងហ្មត់ចត់ចំពោះសិស្សដូចម្តេចដែរ? ពិសេសជាងនេះទៅទៀត យើងត្រូវដឹងថាស្ថាប័នអប់រំរបស់យើងមានស្តង់ដារកម្រិតណា? ចុះការប្រើប្រាស់ពាក្យសម្តី អាកប្បកិរិយា ការរៀបចំខ្លួនរបស់បុគ្គលិកគ្រប់ផ្នែក លោកគ្រូអ្នកគ្រូ តើសមរម្យស្របទៅ

តាមក្រមសីលធម៌ និងចំណេះជំនាញវិជ្ជាជីវៈរបស់គាត់ដែរឬទេ?

ក្រៅពីចំណុចដែលបានរៀបរាប់ខាងលើនេះ នៅមានចំណុចមួយទៀតដែលក្នុងនាមជាស្ថាប័នអប់រំគួរយកចិត្តទុកដាក់ នោះគឺកម្មវិធីសិក្សា និងគុណភាពនៃកម្មវិធីសិក្សាថាតើសមស្របតាមបទដ្ឋាននៃគោលការណ៍អប់រំជាតិ និងកម្មវិធីសិក្សារបស់ក្រសួងដែរឬទេ? ចំណុចមួយទៀតគឺការចេះប្រមើលមើលពីអនាគតនៃសមិទ្ធផលដែលយើងបណ្តុះបណ្តាលបាន ថាតើថ្ងៃក្រោយបន្ទាប់ពីពួកគេបញ្ចប់ការសិក្សាពីស្ថាប័នយើងទៅ គេអាចយកចំណេះដឹងទៅបន្តការសិក្សានៅថ្នាក់បន្ត ឬអាចយកទៅប្រកួតប្រជែងជាមួយនឹងទីផ្សារការងារទាំងកម្រិតជាតិនិងអន្តរជាតិបានដែរឬទេជាដើម។ ទាំងនេះជាឧទាហរណ៍មួយ ក្នុងចំណោមឧទាហរណ៍ឯទៀតស្តែងពីគុណភាពដែលខ្ញុំ និងស្ថាប័នខ្ញុំតែងប្រតិបត្តិជាប្រក្រតី។ ទោះបីនេះជាបទពិសោធដែលខ្ញុំលើកឧទាហរណ៍ពីស្ថាប័នអប់រំរបស់ខ្ញុំក្តី ក៏ប៉ុន្តែនៅក្នុងស្ថាប័នដទៃៗទៀត ឬការប្រកបរបរអាជីវកម្មផ្សេងៗ ក៏អ្នកគួរតែគិតគូរពីចំណុចទាំងឡាយដែលខ្ញុំបានរៀបរាប់ខាងលើទៅតាមលំនាំ និងសភាពជាក់ស្តែងនៃស្ថាប័នរៀងខ្លួនទៅចុះ។

ខ្ញុំជឿថាយើងពិតជាដឹង និងនិយាយយ៉ាងរត់មាត់ទៅហើយចំពោះអ្វីទៅដែលហៅថាគុណភាពនោះ។ ប៉ុន្តែចំណុចដែលសំខាន់ គឺស្ថិតនៅលើសមត្ថភាពអនុវត្តរបស់យើងតែប៉ុណ្ណោះ។ ដូច្នេះអ្នកជំនួញជោគជ័យ ធ្វើអ្វីក៏ដោយត្រូវមានអត្តសញ្ញាណពិសេសផ្ទាល់ខ្លួនច្បាស់លាស់ និងផ្តោតជាសំខាន់ទៅលើគុណភាពនៃផលិតផល ឬសេវាកម្មរបស់ខ្លួន ហើយអ្វីដែលអ្នកគួរតែកុំធ្វេសប្រហែសក្នុងការធ្វើអាជីវកម្មនោះ គឺការយកចិត្តទុកដាក់លើធនធានមនុស្សភាគីពាក់ព័ន្ធនានា កត្តាពាក់ព័ន្ធ វិស័យពាក់ព័ន្ធ រួមទាំងមជ្ឈដ្ឋានខាងក្នុងនិងខាងក្រៅស្ថាប័ន។

> រៀនអ្វីរៀនឱ្យពិត រៀនយកគំនិត
> រៀនគិតឱ្យចេះ រៀនយកចំណេះ
> រៀនត្រិះឱ្យឆ្លាត

# ទស្សនៈអាជីវកម្ម
## និយមន័យជោគជ័យផ្ទាល់ខ្លួន

*ជោគជ័យ គឺតែងតែបានមកពីការព្យាយាម ឱកាស និងសំណាងរបស់អ្នក។ អ្នកកើតមកសុទ្ធតែមានវាសនាល្អ ហើយបើមានវាសនាបានន័យថាមានឱកាសហើយ។ អ្នកណាក៏មានឱកាសដែរ បើមានឱកាសហើយ ចំពោះអ្នកមានការព្យាយាមឬក៏អត់គឺបិតលើអ្នក។ បើគ្មានការព្យាយាមក៏អត់ជោគជ័យដែរ ដូច្នេះត្រូវចាំឱ្យច្បាស់។ អ្នកជាអ្នកដឹកនាំខ្លួនអ្នកផ្ទាល់ អ្នកជាជនគំរូសម្រាប់ខ្លួនអ្នក ដូច្នេះអ្នកគួរតែជាបុគ្គលដែលមានមនសិការ។ អ្នកអាចថែរក្សាការពារជនទាំងឡាយ ប៉ុន្តែមិនមែនដាក់ខ្លួនដូចជាបម្រើគេទេ អ្នកត្រូវចាំបាច់ផ្តល់តម្លៃដល់ពួកគេ ប៉ុន្តែអ្នកក៏ត្រូវចេះផ្តល់តម្លៃដល់ខ្លួនអ្នកផងដែរ។ អ្នកត្រូវចេះសិក្សាសង្កេតពីពួកគេទាំងនោះ និងរើសយកចំណុចល្អៗមកអនុវត្តចំពោះខ្លួនអ្នក ហើយខិតខំពង្រឹងចំណុចល្អទាំងនោះ បន្ទាប់មកត្រូវដើរទន្ទឹមគ្នាដើម្បីធ្វើការជាមួយពួកគេ និងទទួលបានភាពរីកចម្រើនជាមួយគ្នា។ នោះហើយគឺជាមធ្យោបាយតែមួយគត់សម្រាប់យកឈ្នះនូវភាពអសកម្មទាំងឡាយ ដែលកើតមានចំពោះអ្នក និងសង្គមជាតិរបស់អ្នក៕*

**MENGLY J. QUACH**
**University Press**

*អាសយដ្ឋានៈ អគារលេខ១៤០ និង២១០ មហាវិថីម៉ៅសេទុង រាជធានីភ្នំពេញ*
*ទូរសព្ទៈ ០២៣ ២២៣ ២៩៥, ០២៣ ២២១ ២២២, ០១១ ៣៨៨ ៨៦៨*
*និង ០៩៣ ២១៧ ២១៧*
*អ៊ីមែលៈ* info@mjqeducation.edu.kh
*គេហទំព័រៈ* www.mjqeducation.edu.kh
*រក្សាសិទ្ធិៈ សាកលវិទ្យាល័យ ម៉េងលី ជេ. គួច, គ.ស. ២០១៦*

9 789924 508021